## វប្បធម៌ប៉ាមីយ៉ាន់ (Bamiyan culture Landscape and Archaeological )

ប៉ាមីយ៉ាន់ **(Bamiyan)** គឺជាតំបន់វប្បធម៌ និងក៏ជាស្ថានីយ៍បុរាណវិទ្យាដ៏សំខាន់នៅតាមតំបន់ជ្រលងភ្នំ គុស (Kush) ក្នុងខេត្តប៉ាមីយ៉ាន់ដែលស្ថិត នៅតំបន់កណ្ដាលនៃប្រទេសអាហ្គានីស្ថាន (Afghanistan) ហើយមានចម្ងាយប្រមាណជាង ១០០គីឡូពីរាជធានីកាបុល (Kabul) (រូបលេខ១-២)។

តំបន់នេះ គឺជាផ្លូវពាណិជ្ជកម្មដ៏សំខាន់មួយក្នុងបណ្ដាញផ្លូវសូត្រ ដែលតភ្ជាប់ពីឥណ្ឌាទៅកាន់តំបន់មជ្ឈិមបូព៌ា និងចិនដោយឆ្លងកាត់តំបន់បុរាណ (បាក់តេរី) Bactria បច្ចុប្បន្នជាប្រទេអាហ្គានីស្ថាន និងជាតំបន់នៃការរីកចម្រើនខាងសាសនាដ៏ខ្លាំងក្លាមួយជាពិសេសព្រះពុទ្ធសាសនាតាំងពីស.វ.ទី១ ដល់ស.វ.ទី៩ និងសាសនាអ៊ីស្លាម។[១] ព្រះពុទ្ធសាសនានៅទីនេះ គឺទទួលឥទ្ធិពលពីសិល្បៈវប្បធម៌ Gandhara ដែលជាសិល្បៈព្រះពុទ្ធសាសនាដ៏សំខាន់ក្នុងតំបន់មជ្ឈិមបូព៌ា។

នៅតំបន់ប៉ាមីយ៉ាន់ ឃើញមានសំណង់ជាច្រើនដែលកសាងនៅលើជ្រលងភ្នំ គុស ដូចសំណង់ប្រាសាទ ប៉ុន្តែបច្ចុប្បន្នត្រូវបានខូចខាត ខ្លះនៅសល់តែគ្រឹះ និងខ្លះទៀត ស្ទើរបាត់រូបរាងទាំងស្រុង។ ជាពិសេសសំណង់ព្រះពុទ្ធរូបឈរចំនួនពីរអង្គ មានទំហំយ៉ាងធំហើយមានកម្ពស់ខ្ពស់ ដែលឆ្លាក់នៅជាប់នឹងជញ្ជាំងភ្នំ។ ពុទ្ធរូបមួយមានកម្ពស់ជិត៤០ម៉ែត្រ និងមួយអង្គទៀតមានកម្ពស់ជាង៥៥ម៉ែត្រ។[២] ទម្រង់ព្រះភក្រ័ និងក្បួនសក់ គឺស្ទើរតែដូចទៅនឹងព្រះពុទ្ធនៅតំបន់ Gandhara។ សំណង់ពុទ្ធរូបទាំងពីរអង្គនេះ គឺកសាងនៅអំឡុងស.វ.ទី៦ និងទី៧ នៃគ.ស. ប៉ុន្តែនៅអំឡុងឆ្នាំ២០០១ ពុទ្ធរូបទាំងពីរអង្គ ត្រូវបានក្រុមសាសនាអ៊ីស្លាម (តាលីបង់) បំផ្ទុះបំផ្លាញទាំងស្រុង នៅសល់ត្រឹមតែស្លាកស្នាមនៃរូបរាង

[១] សូមអាន ៖ https://en.unesco.org/silkroad/content/bamiyan

[២] សូមអាន ៖ https://www.nationalgeographic.com/history/article/the-daring-journey-to-reach-afghanistans-famous-buddhas

អត្ថបទដោយ៖ អេង តុលា

តែប៉ុណ្ណោះ។[៣] គួរបញ្ជាក់ដែរថា តំបន់ប៉ាមីយ៉ាន់ត្រូវបានផ្លាស់ប្តូរពីពុទ្ធសាសនាទៅអ៊ីស្លាម នៅអំឡុងស.វ.ទី១០ និងរហូតដល់ឆ្នាំ ២០០១ ទើបក្រុមសាសនាជ្រុលនិយមបានបំផ្លាញរូបនេះទាំងស្រុង និងក្រោយមកនៅឆ្នាំ២០០៧ តំបន់ប៉ាមីយ៉ាន់ត្រូវបានដាក់ចូលជាតំបន់បេតិកភណ្ឌពិភពលោក ដើម្បីការពារ និងជួសជុលរូបដែលបានខូចខាតឡើងវិញ។[៤] (រូបលេខ ៣-៦)។ ក្រៅពីសំណង់ពុទ្ធរូប នៅតាមជ្រលងភ្នំផ្សេងទៀត ក៏ឃើញមានរូបគំនូរដែលគូរពីព្រះពុទ្ធ ដូចនៅ *Kakrak Valley Caves* ដែលមានចម្ងាយប្រមាណជាង ៣គីឡូ ពីរូបធំទាំងពីរ។ រូបគំនូរនៅទីនេះភាគច្រើនមានអាយុកាលស្របាលគ្នានឹងព្រះពុទ្ធធំនោះដែរ (រូបលេខ ៧-៩)។[៥] នៅតំបន់ប៉ាមីយ៉ាន់ គេនិយមគូរ ឬឆ្លាក់ពុទ្ធរូបដែលមានទំហំធំ។ តាមរយៈសំណង់ទាំងនោះ អាចឱ្យអ្នកស្រាវជ្រាវយល់បានថា មនុស្សក្នុងតំបន់វប្បធម៌ប៉ាមីយ៉ាន់ មានជំនាញ និងបច្ចេកទេសខ្ពស់ ក្នុងការកសាងសំណង់រូបបដិមាដ៏ធំទាំងនោះ។

ចាប់ពីស.វ.ទី ១០មក ផ្លូវពាណិជ្ជកម្មរវាងចិន និង ឥណ្ឌាត្រូវបានផ្លាស់ប្តូរចេញពីតំបន់ប៉ាមីយ៉ាន់ ដែលធ្វើឱ្យតំបន់នេះធ្លាក់ឥទ្ធិពលរបស់ខ្លួន ហើយចាប់ពីពេលនោះមកតំបន់នេះមានការផ្លាស់ប្តូរសាសនាពីពុទ្ធសាសនា មកអ៊ីស្លាមដែលចាប់ពីរាជស្តេច Ghaznavid។[៦]

ជារួមមកតាមរយៈសំណង់ស្ថាបត្យកម្ម និងសិល្បៈ អ្នកស្រាវជ្រាវបានបង្ហាញពីការវិវឌ្ឍន៍ នៃឥទ្ធិពលសាសនានៅក្នុងតំបន់វប្បធម៌ប៉ាមីយ៉ាន់ អំពីការកសាងព្រះពុទ្ធរូបដ៏ធំមហិមា រហូតដល់ការបំផ្លាញរូបទាំងនោះ ពីសំណាក់ក្រុមជ្រុលនិយមសាសនាអ៊ីស្លាមក្នុងប្រទេសអាហ្គានីស្ថាន។ ឥទ្ធិពលពុទ្ធសាសនាដែលមានការរីកចម្រើនក្នុងតំបន់នេះ គឺចាប់ផ្តើមពីស.វ.ទី១ ដល់ស.វ.ទី ១០នៃគ.ស. រហូតដល់ការជ្រាបចូលនៃសាសនាអ៊ីស្លាមចាប់ពីស.វ. ទី១០ រហូតដល់ពេលបច្ចុប្បន្ន។

---

[៣] សូមអាន ៖ https://whc.unesco.org/en/list/208/

[៤] សូមអាន ៖ https://www.khanacademy.org/humanities/ap-art-history/west-and-central-asia-apahh/central-asia/a/bamiyan-buddhas

[៥] https://whc.unesco.org/en/list/208/

[៦] Ibid

អត្ថបទដោយ៖ អេង តុលា




រូបលេខ១៖ផែនទីនៃតំបន់វប្បធម៌ប៉ាមីយ៉ាន់

ប្រភព៖ https://www.khanacademy.org , ទី ២ UNESCO



រូបលេខ២៖ ទិដ្ឋភាពទូទៅ នាពេលបច្ចុប្បន្ន

ប្រភព៖ https://www.khanacademy.org , ទី ២ UNESCO

អត្ថបទដោយ៖ អេង តុលា



រូបលេខ៧៖ព្រះពុទ្ធរូបឋតក្នុងអំឡុងឆ្នាំ ១៩៨០?

ប្រភព៖ Dr. H. Crane





រូបលេខ៨ និង ៩ ៖ព្រះពុទ្ធរូបឋតមុនពេលត្រូវបានបំផ្លាញ

ប្រភព៖ www.nationalgeographic.com

អត្ថបទដោយ៖ អេង តុលា





រូបលេខ២៦-៧ ៈព្រះពុទ្ធរូបថតមុនពេលត្រូវបានបំផ្លាញ និងរូបទី៨ ៈ រូបបច្ចុប្បន្ន

ប្រភព៖ www.nationalgeographic.com



រូបលេខ២៨ ៈ រូបបច្ចុប្បន្ន

ប្រភព៖ www.nationalgeographic.com អត្ថបទដោយ៖ អេង តុលា



រូបលេខ៩៖ រូបគំនូរនៅក្នុងល្អាងភ្នំក្បែរពុទ្ធរូបធំ

ប្រភព៖ www.nationalgeographic.com

## ឯកសារយោង


https://en.unesco.org/silkroad/content/bamiyan

https://www.nationalgeographic.com/history/article/the-daring-journey-to-reach-afghanistans-famous-buddhas

https://whc.unesco.org/en/list/208/

https://www.khanacademy.org/humanities/ap-art-history/west-and-central-asia-apahh/central-asia/a/bamiyan-buddhas


អរិយធម៌ខ្មែរ KHMER CIVILIZATION

អត្ថបទដោយ៖ អេង តុលា